D59679
TSL

L-157

Lay Len dit Touch

លៀយ ឡេន ឌិ ទូច

យកពី [illegible] ៣ ។ ៣២ ក.ពា.703

ចាប់ 3-10-78

20 ans

ចម្លើយរបស់ឈ្មោះឡាយ.ឡេងហៅ ទូចខុំយុទ្ធផល

កងពិសេសរបស់វ:សេនាធំ៣២កងពល៧០៣ :

ប្រវត្តិសកម្មភាពក្បត់បក្សផ្ទាល់

ធ្វើនៅថ្ងៃទី២២.តុលា១៩៧៨.

**សង្កេត**

មនុស្សនេះ

ខ្ញុំអនុវត្តតាមគោលការសួរដោយមិនធ្លាប់ទីទី

ធ្លានទាំងស្រុង តាំងពីដើមរហូតដល់ចប់ ។

៚ ៚

៚

២២ តុលា 1978

ព្រាក់ · ១៨ ·

## ខ្ញុំសូមរាយការណ៍ជូនអង្គការអំពីប្រវត្តិ
## សកម្មភាពក្បត់របស់ខ្ញុំ

ខ្ញុំឈ្មោះ ឡាយឡេន ហៅ ទូចខុំ អាយុ២០ ឆ្នាំ នៅលីវ ជនជាតិខ្មែរ ។
កំណើតនៅភូមិទីព្រតឹកល ឃុំដំណាក់កន្ទួតស្រុកកំពង់ត្រាច តំបន់៣៥ ភូមិភាគ និរតី ។
ឪពុកឈ្មោះឡាយលន ម្ដាយឈ្មោះទូច ញ៉ាំ នៅរស់ទាំងអស់ ។

មុនអង្គការចាប់ខ្ញុំជាយុទ្ធជនកងពិសេសរបស់វរៈសេនាធំ៣២ កង៧០៣ ។ តាំងពីតូចមកខ្ញុំនៅជាមួយឪពុកម្ដាយធ្វើស្រែនិងធ្វើស្ករត្នោត ហើយចំពោះម្ដាយខ្ញុំគាត់ទក់ស៊ីលក់នំផ្លែដូងទុំបន្តិចបន្តួចនៅផ្សារកំពង់ត្រាចផង ។ ខ្ញុំនៅជាមួយឪពុកម្ដាយរហូតអត់បាន រៀនអក្សរនិងគេទេ ។ ពេលចូលបដិវត្តន៍ទើបខ្ញុំរៀនអក្សរបានប្រហែល ១ ខែ ។

ភូមិរបស់ខ្ញុំរំដោះបាននៅឆ្នាំ១៩៧២ - ។
១៩៧៣ ខ្ញុំចូលបដិវត្តន៍ធ្វើឈ្លបឃុំដំណាក់កន្ទួត ក្នុងស្រុកកំពង់ត្រាច ។ ខ្ញុំនៅធ្វើឈ្លបឃុំដំណាក់កន្ទួតនេះព្រឹមួយឆ្នាំ ដល់ឆ្នាំ១៩៧៤ ទើបអង្គការបញ្ជូនខ្ញុំឱ្យឡើងមកនៅយោធាស្រុកកំពង់ត្រាច រហូតដល់ពេលក្រោយរំដោះទូទាំងប្រទេស អង្គការឱ្យកងទ័ពស្រុកកំពង់ត្រាចទាំងអស់ឡើងមកនៅយោធាតំបន់៣៥ កំពត ក្នុងកងវរៈសេនាតូច ៦៥ ។ ប្រចាំនៅតាមព្រំដែនស្រុកទូកមាស គឺខ្ញុំនៅក្នុងក្រុមរបស់ឈ្មោះ សាត អតីតៈក្ដួចប៉មិនបានទេខ្ញុំស្គាល់និងឃើញនៅពេលដែលខ្ញុំទៅនៅកងតំបន់នោះតែម្ដង ក្រោយពេលដែលខ្ញុំឡើងមកនៅកង៧០៣ គាត់នៅក្នុងកងវរៈសេនាតូច៦៥ របស់តំបន់៣៥ កំពត ភូមិភាគនិរតី នាទីប្រធានក្រុម ។ គាត់តែងបំផុសខ្ញុំអំពីរឿងស្រី ថាពីសង្គមវិញទាក់នារីបានតាមចិត្ត មិនដូចបដិវត្តន៍ទេ ។

រហូតដល់ជិតរដូវធ្វើស្រែប្រហែលខែ៤.៥ នៅពេលកំពង់សាបផ្លែត្រសក់ និងល្ពៅ - មួយថ្ងៃរែកដែកទឹកស្រោចបន្លែជាប់ ហើយរបបហូបពេលនោះក៏មានការខ្វះខាតដែរហូបតែបបរ ម្នាក់បានតែ១កំប៉ុងទេ ១ថ្ងៃពុ ចំពោះខ្ញុំក៏មានធាតុសេរីច្រើនដែរពេលនោះមិត្តយើងក៏សាងខ្ញុំរឿងខ្ជិលធ្វើការងារ និងដើរលួចដំឡូងហូបក៏ខ្ញុំមិនស្ដាប់ ។ ហើយពេលធ្វើ

ការចាត់អ្នកសេរីដូចគ្នាពុំតែងមកសំរាក់ជុំគ្នាជាមួយបងសាត   គឺមានឈ្មោះ

១- ទូច   អតីតៈក្តាប់មិនបាន ទើបតែស្គាល់ឆ្នាំ៧០ទេ បច្ចុប្បន្នយុទ្ធជន
នៅវរៈសេនាតូចលេខ៦៥របស់កងតំបន់កំពត ភាគនិរតី ។

២- គុយ   អតីតៈក្តាប់មិនបាន ទើបតែមកស្គាល់គ្នានៅ៧០ទេ បច្ចុប្បន្ន
មេពួកនៃកងវរៈសេនាតូចលេខ៦៥ របស់តំបន់កំពតដែរ ។

ព្រោះចូលចិត្តបងស្ដាប់បងសាតគាត់និយាយពីរឿងស្រី ។ ពេលនេះបងសាតគាត់បានសួរមកខ្ញុំថា ខ្ញុំឯងចង់បានប្រពន្ធទេ ខ្ញុំប្រាប់គាត់ថាមិនទាន់ចង់បានទេ ហើយបានគាត់និយាយទៀតថា កាលពីសង្គមចាស់វិញ ដូចយើងទាំងអស់គ្នានេះ បើខូចស្រីបានតាមចិត្ត មិនដូចក្នុងសង្គមបដិវត្តទេ ធ្វើមិនស្រួលហ្នឹងអង្គការយកទៅផ្ចាន់ហើយ ។ គាត់និយាទៀតថាសព្វថ្ងៃនេះឯងដឹងទេតស៊ូវណ្ណៈតឹងតែងណាស់ ទ័ពស្គមអស់ហើយ បើពីសង្គមចាស់វិញខ្ញុំមិនដូចនេះទេ ឱ្យតែធ្វើស្រែហើយដកហើយ និងដើរមើលបុណ្យដើរលេងតែម្តង កាលពីមុនគ្មាននរណាគេធ្វើដូចនេះទេ ។ មើលសព្វថ្ងៃសង្គមបដិវត្តធ្វើស្រែហើយបានដើរលេងបៀរអាប៉ោងទាក់ទងនារីបានតាមចិត្តនោះទេ ឱ្យតែអ្នកណាហ៊ានធ្វើមុកជាអង្គការយកទៅបាត់ហើយ - សង្គមបដិវត្តយើងឥឡូវនេះពិបាកណាស់ មិត្តមើលរកប្រពន្ធខ្លួនឯងមិនបាន ដើរលេងមិនបាន ធ្វើការសេរីមិនបាន និយាយស្តីមិនបានតាមចិត្តទេ សូម្បីតែអត់មានចាយ បាយក៏អត់មានស៊ី - ហើយធ្វើការជាប់ ។

ចូលមកដល់រដូវធ្វើស្រែឆ្នាំ៧២នោះអង្គភាពរបស់ខ្ញុំធ្វើស្រែនៅទីព្រៃទន្លេជាប់និងក្រុំដែន គឺទៀងតាំងពីម៉ោង ២.៣. ល្ងាចតាមស្រែជិតឆ្ងាយ ពេលធ្វើស្រែនេះពេលឈប់សំរាក់ម្តងៗខ្ញុំនិង មិត្តទូច មិត្តគុយតែងទៅអង្គុយជុំគ្នាជាមួយនិងបងសាត ហើយបងសាតគាត់ក៏បានអប់រំមកពួកខ្ញុំម្តងទៀត គាត់និយាយថា មិត្តឯងមើលហ្នឹងហើយការតស៊ូវណ្ណៈឱ្យ - យើងធ្វើរបៀបហ្នឹង ខ្លាំងរបៀបហ្នឹងគង់តែងាប់ទាំងអស់ទេ ស៊ីក៏មិនឆ្អែតហូបតែទឹកបបរ - ទទេៗ ហើយអត់បានដេកទៀតបានកម្លាំងឯណាធ្វើការទេ គាត់សួរមកខ្ញុំនិងទូច គុយថាអញ្ចឹងមែនទេ ខ្ញុំថាអញ្ចឹងហើយ ព្រោះខ្ញុំក៏ស្គមដែរ គាត់ថាប្រយ័ត្នងាប់ខ្លួនហើយធ្វើឱ្យ

តែរូបពុំទៅបានហើយ មិនមែនយកទៅឱ្យភាណាស៊ីទេ ។ ពេលសំរាកលើកក្រោយទៀត គឺគាត់លើកយករឿងនេះមកនិយាយទៀត និងរឿងសីលធម៌ និងកាលំបាក ស៊ីមិនឆ្អែត ធ្វើការច្រើន ។

ថ្ងៃមួយគាត់បានសួរខ្ញុំនិងទូចគុយថា មិត្តឯងចង់បានមួយស៊ីឆ្អែតទេ បើចង់បានស្រួលដូចពីសង្គមចាស់ធ្វើតាមខ្ញុំទៅ ពួកខ្ញុំថាចឹមិនចង់ដូចពីដើម ព្រោះធ្វើការច្រើនណាស់ឡើងទៅធ្វើស្រែតាំងពីម៉ោង២.៣.យប់ដល់ម៉ោង១១ គ្មានពេលណាទៅរួចទេ ។ គាត់ថា - កាលពីសង្គមចាស់ស្រួលណាស់ព្រោះឯកជនយើងធ្វើអីក៏បានតាមចិត្ត ស៊ីកងកជន បើសង្គមបដិវត្តវិញ ធ្វើការក៏រួម ស៊ីក៏រួម ចំណីឆ្ងាញ់ៗស៊ីមិនដែលបានឆ្អែតទេ ទាល់តែសមូហភាព មិនសមូហភាពទេក៏សាង បើចង់បានដូចពីសង្គមចាស់ទាល់តែធ្វើតាមខ្ញុំ គឺប្រឆាំងបដិវត្ត ប្រឆាំងនឹងរបបសមូហភាពឱ្យអស់ ដូចជាបដិវត្តឱ្យយើងធ្វើការ យើងធ្វើឱ្យតែរួចពីដៃទៅ កុំឱ្យបានផលបដិវត្តឱ្យដាំដំឡូង ដូងល្ពៅ ដែលទុកពូជក្តី យើងលួចមកកាប់ស៊ីស្ងោរស៊ីឱ្យអស់ ដើម្បីយើងបំផ្លាញសមូហភាព ។

ក្រោយពីគាត់បានអប់រំណែនាំហើយមកខ្ញុំជាមួយបងសាត និងមិត្តគុយ ទូច បានលួចយកត្រលក់ និងល្ពៅដែលទុកពូជមកស្ងោរស៊ី ដូងសមូហភាពដាំលួចកាប់ក្រពើងស៊ី ពេលយាមយប់លួចគាស់ដំឡូងស៊ី ធ្វើការលេងពុចាឱ្យតែដល់ម៉ោងបាយប៉ុណ្ណោះ ការងារដែលធ្វើហើយក្រឆក់ក្រឆែងដោយមិនពេញចិត្ត ។

ពេលជិតផុតរដូវស្ទូងហើយបងសាតគាត់បានណែនាំខ្ញុំនិងមិត្តគុយ មិត្តទូចថា យើងធ្វើនេះធ្វើសេអ៊ីអា ប្រឆាំងនិងបដិវត្ត សហការជាមួយនិងយួន " បញ្ជាក់គាត់មិនបានប្រាប់ឱ្យស្គាល់ឈ្មោះយួនទេ " ដូច្នេះពួកយើងទាំងអស់គ្នាត្រូវប្រមូលកម្លាំងបន្ថែមទៀត មើលទាក់ទងមិត្តណាខ្លះនៅកងជាមួយនិងយើងមានធាតុសេរីពុ ទាក់ទងឱ្យបានមកឱ្យខ្ញុំជួយអប់រំ ដើម្បីឱ្យបានគ្នាយើងច្រើន ហើយអ្នកដឹកនាំយើងក៏មិនតូចដែរ គឺបងចន គណៈវរៈសេនាធំតំបន់៣៥ កំពត ឆ្នាំ១៩៧៦ អង្គការឱ្យទៅក្តាប់រោងចក្រជីរនៅទូកមាស បច្ចុប្បន្ននេះក្តាប់មិនបាន ក៏គ្នាយើងដែរយើងទៅព្រួយអី ។ មួយទៀតយើងត្រូវធ្វើសកម្មភាពបំផុស ៸

យុទ្ធជនណា ដែលលើទីពុំឱ្យរត់ទៅផ្ទះ ដើម្បីឱ្យខ្សោយកម្លាំងបដិវត្ត មិត្តមើលអ្នកណា សៀវ លឹកផ្ទះ យើងត្រូវបំផុសគេថា បើអ្នកណារត់ទៅនៅមូលដ្ឋានវិញ គេរៀបគ្រួសាឱ្យហើយៗ តែយើងត្រូវចេះលាក់កុំឱ្យបែកការ គេដឹងថា យើងជាខ្មែរសេអ៊ីសា ទាក់ទងជាមួយនប្រឆាំងបដិវត្ត ហើយយើងចំប្រមូលកម្លាំងឱ្យបានច្រើន បានឆាប់ឈ្នះបដិវត្ត និងរបបសមូហភាព-

ក្រោយគាត់បានណែនាំមកខ្ញុំបានធ្វើសកម្មភាពបំផុសមិត្តយើងឱ្យរត់ទៅផ្ទះអស់ម្នាក់ ៗ ដោយខ្ញុំបំផុសគេថា ធ្វើការលំបាកណាស់ទៀងតាំងពីម៉ោងពីរ ម៉ោង៣ ហើយស៊ីមិនគ្រប់គ្រាន់ បើទៅនៅមូលដ្ឋានគេរៀបគ្រួសារឱ្យ ។ ចំពោះបងសាត មិត្តសុយ ទូចខ្ញុំភ្ជាប់មិនបាន ទេកាលណ្ណោះ តែក្នុងឆ្នាំ៧៦នោះកងរបស់ខ្ញុំរត់អស់គ្នា ១២នាក់ ។

ក្រោយមកទៀតខ្ញុំមានភារកិច្ចឃ្វាលគោពនឹមមិនបានទៅយាមទេ ព្រំដែននិង គេទេ ចំពោះបងសាត និងមិត្តសុយ ទូចគេមានភារៈកិច្ចយាមការពារព្រំដែន តែខ្ញុំឃ្វាលគោ ក៏នៅជិតព្រំដែនដែរ ហើយពួនកាលណ្ណោះនៅជាប់នឹងរបងព្រំដែន ។ ពេលខ្ញុំនៅឃ្វាលគោ នេះបានធ្វើសកម្មភាពឱ្យបាត់គោអស់មួយនឹម ដោយខ្ញុំបណ្តែតបណ្តោយឱ្យវាឆ្លងចូលទៅក្នុងសីយួន ហើយមិនហ៊ានតាមទៅចាប់ ។

នៅចុងឆ្នាំ១៩៧៦-នោះដែលបងសាតគាត់បានប្រាប់ខ្ញុំ និងមិត្តទូច សុយ ថាលព្វ៍ថ្ងៃនេះ អ្នកដាក់ផែនការឱ្យគាត់ផ្ទាល់គឺមានឈ្មោះបងរ៉េត ពីដើមមកខ្ញុំមិនដែលស្គាល់ទេ បច្ចុប្បន្ន កងហានៅវរៈសេនាតូចលេខ១៦៥ កងតំបន់ ៣៥កំពត ហើយបងរ៉េតនេះគាត់អ្នកទៀងទៅ ទទួលផែនការផ្ទាល់ពីបងចនវរៈសេនាធំ បងសាតគាត់បានប្រាប់បន្ថែមទៀតថា កម្លាំងរបស់ បងរ៉េតមានម្នាក់ទៀត គឺឈ្មោះ សឿន ពីដើមមកក៏ខ្ញុំមិនដែលបានស្គាល់ដែរ ទើបមក-ស្គាល់គាត់នៅកងជាមួយគ្នាទេ បច្ចុប្បន្នអនុក្រុមទី៣ កងហាទី២ កងធំ៣៤ វរៈសេនាតូច លេខ១៦៥ តំបន់កំពត ភូមិភាគនិរតី ។ ដូច្នេះយើងត្រូវទាក់ទងគ្នាឱ្យជាប់ដើម្បីធ្វើសកម្មភាពនៅក្នុងអង្គភាពរបស់យើងឱ្យមានការស្មុគស្មាញ ។

ក្រោយមកពេលខ្ញុំមកពីស្រោចទឹកបន្លែវិញ ដើរតាមភ្លឺស្រែមកផ្ទះ ក៏បានជួបបង-រ៉េតនៅកណ្តាលភ្លឺស្រែ ដំបូងគាត់សួរខ្ញុំពីរឿងដាំបន្លែបានយ៉ាងម៉េចហើយ ទើបគាត់សួរខ្ញុំ

ថាយ៉ាងម៉េចហើយមិត្តឯងជាមួយសាតនោះមានដឹងទេ ខ្ញុំថារឿងអីបង គាត់ថាមិនច្បាស់លាក់ទេសាតប្រាប់គាត់ហើយ សាតមានអប់រំមិត្តឯងទេ ពេលនោះខ្ញុំក៏ប្រាប់គាត់ថាបងសាតបានអប់រំខ្ញុំដែរ គាត់ថា អើយើងធ្វើម៉េចអំលាក់ការរៀននេះឱ្យបានកុំឱ្យបែកការ

ហើយគាត់ណែនាំខ្ញុំថា ឥឡូវនេះមិត្តឯងធ្វើការជាមួយនិងមិត្តសាតចុះព្រោះគាត់បានណែនាំទៅមិត្តសាតហើយ ៗ និយាយគ្នារួចក៏បែកគ្នាមកផ្ទះវិញ ៗ

នៅពេលធ្វើស្រែប្រាំងចុងឆ្នាំ៧៦ ខ្ញុំនិងមិត្តគុយ ទូច បងសាតខ្ជិលទៅធ្វើស្រែនាំគ្នាពុតធ្វើជាឈឺទាំងអស់គ្នា មិនសូវបានទៅធ្វើការទេ ៗ ហើយពេលនៅផ្ទះនោះក៏នាំគ្នាលួចដំឡូងនិងល្ពៅទុំមកស្ងោរហូបមួយចំអែតពុជាបន្តបន្ទាប់ ធ្វើឱ្យមានការស្មុគស្មាញជាប់នៅក្នុងអង្គភាពដោះស្រាយមិនចេញ ម្តងបាត់នេះម្តងបាត់នោះ ៗ
ចុងឆ្នាំ១៩៧៦ និងដើម៧៧ ខ្ញុំនិងអង្គភាពរបស់ខ្ញុំឈប់ធ្វើស្រែមកសំរាក់នៅខាងក្រោយតាមភូមិចាស់របស់ចុបជាជនដើម្បីត្រៀមកម្លាំងទៅវ៉ៃយួននៅតាមព្រំដែន ៗ សំរាក់ក្រោយបានមួយរយៈ កងរបស់ខ្ញុំត្រូវទៅវ៉ៃជាមួយយួននៅសមរភូមិក្បូនត្រុំដែលវាឈ្លាននៅលើដីខ្មែរ ពេលនេះបងសាតគាត់បានហៅខ្ញុំ និងមិត្តគុយ ទូចមកណែនាំថា ពេលវ៉ៃនៅសមរភូមិនេះយើងត្រូវធ្វើសកម្មភាព ពេលមិត្តយើងទៀងសំរុកកុំឱ្យទៀង និងឱ្យរត់ចោលខ្សែត្រៀម រត់ចោលជួរ ដើម្បីឱ្យកម្លាំងយួនកំទេចកម្លាំងបដិវត្ត ៗ មួយទៀតពេលមិត្តយើងសំរុកចូលទៅមុខយើងនៅពីក្រោយត្រូវបាញ់កម្លាំងបដិវត្តពីក្រោយខ្នង និងបំផុសចលនានៅក្នុងជួរឱ្យខ្លាចសមរភូមិ ថាកម្លាំងយួនខ្លាំង យួនពីទូមកពីខាងនេះនោះនៅមិនបានទេ ត្រូវតែរត់ចេញពីសមរភូមិប្រយ័ត្នងាប់ខានសប្បាយ ៗ

ពេលទៅវ៉ៃនៅសមរភូមិក្អូនត្រុំ សភាពការណ៍មិត្តយើងកំពង់តែវ៉ៃខ្លាំងយួនជិតបាក់ ហើយបងសាតនិងខ្ញុំគុយ ទូច បានធ្វើសកម្មភាពបំផុសតាមខ្សែត្រៀមថាដកពួយួនពីទូហើយ ៗ ពេលនោះមិត្តយើងក៏ដក ឃើញដកដូច្នេះយួនក៏ស្កាត់ផ្លូវពីទូដាប់មិត្តយើងមួយចំនួនលើចង្កេះភ្នំ មួយចំនួនទៀតក៏រត់រួចទាន់ ពួកខ្ញុំក៏រត់រួចមកក្រោយដែរហើយបាញ់មិត្តយើងស្លាប់អស់១នាក់

ឯកម្លាំងមិត្តយើងដែលយួនពីទូដាប់នៅលើចង្កេះភ្នំដល់យប់យួនដកទៅវិញទើប

ចេញមកវិញ តែបាត់ខ្លួនអស់មួយចំនួនដែរ ។ ហើយបន្ទាប់នោះក៏ដៃមិនបែកទេ ។ ហើយបន្ទាប់នេះក្រោយពុមកក៏ចេះតែដៃជាបន្តបន្ទាប់ទៀត ចំពោះខ្ញុំ មិត្តទូច គុយ - និងមិត្តសឿនបងសាត បានពុះធ្វើជាឈើមិនទៅវៃលួនជាបន្តបន្ទាប់ ទោះឈើក្បាលបន្តិចបន្តួចក៏មិនទៅច្បាំងដែរ ។ បញ្ហាកមិត្តសឿនមិញវិបានធ្វើសកម្មភាពជាមួយនិងខ្ញុំទេព្រោះគេនៅកងផ្សេងខុសគ្នា ។

ប្រហែលជាកណ្តាលឆ្នាំ ៧៧ខ្ញុំអត់ចាំខែអង្គការដកខ្ញុំ និងមិត្តទូច គុយ ទៅនៅកងពិសេសរបស់តំបន់៣៥ដែរ តែទៅការពារឈ្លបមុត្រជំនួលស្មើរដើង ពេលនេះខ្ញុំត្រូវបែកពីបងសាត បងវេត និងមិត្តសឿនហើយ ។ ពេលនេះពួកខ្ញុំអត់ទាន់ហ៊ានធ្វើសកម្មភាពអីទេ រហូតពេលយួនវៃចូលដល់ខ្ញុំនៅសមរភូមិភ្នំលក ។ ដល់ពេលយួនទៅវិញអស់ទើបអង្គភាពរបស់ខ្ញុំលេខ១៥ជាកងពិសេសរបស់តំបន់ត្រូវឡើងមកកងទ័ពភូមិភាគនីរតីវិញ ចូលដល់ឆ្នាំ៧៨ហើយៗ មកសំរាកនៅជិតក្រុងតាកែវក្នុងឃុំខ្វាវ ពេលនេះទើបខ្ញុំមានខ្សែទាក់ទងឡើងវិញ - ទាំងអស់គ្នាជាមួយនិងឈ្មោះ ស៊ុម អតីតៈធ្វើទាហាន១ខែនៅកំពត់ បច្ចុប្បន្ន កងហានៅកងពិសេសរបស់វរៈសេនាធំ៣២ កងពល៧០៣ ប្រចាំនៅភូមិបូពារ៍ ។ មុនដំបូងបងស៊ុមន៍គាត់ជាកងហាររបស់ខ្ញុំ បានមួយរយៈទើបគាត់ទៅធ្វើកងហារផ្សេងទៀត តែនៅក្នុងកងអនុសេនាធំជាមួយគ្នាទេ ជួបមុខគ្នាព្រឹកល្ងាច ។ គាត់ចូលចិត្តលេងសើចជាមួយនិងខ្ញុំណាស់ និយាយលេងសើចរាល់ថ្ងៃតែពីរឿងស្រី និងពុករលួយអាវ៉ាដែស គាត់អួតប្រាប់ខ្ញុំថាពីដើមសប្បាយណាស់ នារីលេងតាមចិត្តចង់យកប៉ុន្មានក៏បានដែរ ហើយខ្ញុំក៏ឃើញដំណើររបស់គាត់ដើររាយសង្ហាកាច់រាង និងប៉ិនដើរទាក់ទងញ៉ែនារី ហើយខ្ញុំក៏ដឹងចិត្តគាត់ទៀតផង ខ្ញុំនិយាយលេងថាបងស៊ុមបើធ្វើទាហានមិនដឹងឡូយយ៉ាងណាទេបើរាងសង្ហាយ៉ាងនេះ គាត់ថាឯងកាលពីនៅធ្វើទាហានកំពតឡូយដល់ហើយមួយថ្ងៃពុមានធ្វើអីដេកតែស៊ីយាមបន្ទាយនិងដើរលេងស្រី -

ប៉ុណ្ណោះ ។ ខ្ញុំសួរថាចុះបងធ្វើទាហានបានប៉ុន្មានខែ ឈប់ពីរឆ្នាំណា គាត់ថាធ្វើបានតែមួយខែទេ ហើយគាត់មករកស៊ីលក់ទឹកកកនៅផ្សារកំពត. ព្រោះធ្វើទាហានបានប្រាក់ខែតិចពេក ឯងនៅលក់ទឹកកកតាំងពី៧១ដល់៧២មកនៅរកស៊ីធ្វើស្រែផ្ទះវិញ រហូត

ដល់៧ខែទើបគាត់ផ្លូលបជីវិតនៅកងចល័តតំបន់៣៥កំពត ។ គាត់និយាយទៀតថាសព្វថ្ងៃនេះរកសប្បាយអីបន្តិចមិនបានសោះ ធ្វើមិនស្រួលហើយគេទិតៀនទៀត ។ គាត់សួរខ្ញុំថាខ្ញុំឯងធ្វើការជាមួយខ្ញុំអី ខ្ញុំថាធ្វើអី គាត់ថាឱ្យថាធ្វើ ខ្ញុំថាអីមិនធ្វើ គាត់ថាបើយើងទាមទាររបបចាស់មកវិញ ដែលបបសប្បាយហើយ ខ្ញុំថាធ្វើយ៉ាងម៉េចបើគ្នាតិចអញ្ចឹង គាត់-ថាយើងទាក់ទងប្រមូលខ្សែសង្វាក់យូពុះទៅ បានច្រើនហើយ ។ គាត់សួរមកខ្ញុំទៀតថាខ្ញុំឯងសុខចិត្តធ្វើសកម្មភាពបង្កប់ទីផ្នែកក្នុង ក្នុងជីវិតជាមួយគាត់ទេ ខ្ញុំថាបើមានបងដឹកនាំធ្វើសកម្មភាពនេះខ្ញុំធ្វើជាមួយបងទៀត ព្រោះកាលពីខ្ញុំនៅកងតំបន់៣៥ ក៏មានបងសាត និងបងទ័ត បងចនវរៈសេនាធំ៦៥ដឹកនាំធ្វើសកម្មភាពដែរ ហើយកម្លាំងដែលធ្លាប់ធ្វើសកម្មភាពជាមួយខ្ញុំពីមុនឥឡូវនេះមកនៅជាមួយខ្ញុំពីរនាក់ដែរ គឺមានឈ្មោះ គុយនិង ទូច ។

ពេលនោះបងស៊ឹម គាត់ក៏បានប្រាប់ខ្ញុំថា កាលពីនៅតំបន់កំពតគាត់ក៏មានខ្សែគាត់ម្នាក់ដែរជានាក់ដឹកនាំ គឺឈ្មោះ ទីជ អតីតៈមិនដឹង កាណោះគណៈវរៈសេនាធំ៥១របស់តំបន់៣៥កំពត បច្ចុប្បន្ននេះភ្ជាប់មិនបានទេ គាត់ទើបតែមកនៅកងចល័តភូមិភាគនេះអត់ទាន់មានខ្សែសង្វាក់អីទេកំពង់តែរកប្រមូលកម្លាំងទៀត ។

ចាប់ពីពេលនោះមកខ្ញុំក៏បានជាប់ខ្សែជាមួយនិងបងស៊ឹមរហូតមកដល់សព្វថ្ងៃនេះ ។ ដើម៧៨ក្រោយពីសភាគការណ៍យួនទៅពីដីខ្មែរអស់អង្គភាពរបស់ខ្ញុំមានភារៈទៅវ៉ៃនៅទីតាំងរបស់យួននៅ ភ្នំអកយំពេលនេះ បងស៊ឹមគាត់បានណែនាំខ្ញុំនិងមិត្តគុយ មិត្តទូច ថាយើងទៅវ៉ៃនៅសមរភូមិនេះទៅតាមតែទៅចុះពេលណាសំរុកយើងមិនបាច់សំរុកទេនៅតែពីក្រោយគេបានហើយ ចាំយើងបាញ់ពីក្រោយវិញ ដើម្បីឱ្យខូចខាតដល់កម្លាំងបដិវត្ត ។

ដល់ពេលសំរុកចូលនៅបន្ទាយភ្នំអកយំ បងស៊ឹមខ្ញុំ និងមិត្តគុយ ទូច បានគេចមកនៅខាងក្រោយអត់ទៀងទៅសំរុកទេ ដល់ពេលមិត្តយើងសំរុកចូលបានបាញ់ពីក្រោយទៅវិញ បណ្តាលឱ្យស្លាប់មិត្តយើងអស់ម្នាក់ ។ ហើយសមរភូមិនេះក៏ត្រូវយួនព័ទ្ធជាប់ទៀត តែក្រោយមករត់រួចមកវិញអស់ ដោយយួនវាដកទៅវិញ ។

ទីវ៉ៃសមរភូមិនេះហើយកងរបស់ខ្ញុំក៏ដកមកសំរាកនៅខាងកើតភ្នំដិន ពេលនេះបងស៊ឹម

បានហៅខ្ញុំ និងមិត្តគុយ ទូច មកណែនាំថា ក្នុងសមរភូមិនេះយើងធ្វើសកម្មភាពឈ្នះហើយដូច្នេះ សមរភូមិក្រោយទៀតក៏យើងធ្វើទៀតដែរ តែឥឡូវនេះយើងទាំងអស់គ្នាត្រូវប្រមូលកេ កម្លាំងម្តង ពិនិត្យមើលអ្នកណាសេរីៗ ខ្លាចសមរភូមិ យើងត្រូវអូសទាញគេជំរះគេមើល តើគេសុខចិត្តធ្វើសកម្មភាពជាមួយនិងយើងទេ ហើយយើងទាំងគ្នាត្រូវលាក់ការណ៍ឱ្យមែន - ទែនកុំឱ្យបែកការ តែបែកកកបរស្លាប់ទាំងអស់គ្នាហើយ ។ ពេលនោះខ្ញុំថាលាក់ការណ៍ បាន តែខ្ញុំមិនចេះនយោបាយអប់រំគេទេ ព្រោះគ្មានស្រីស្តី គាត់ថាបើមិនចេះអប់រំ គេទេ ត្រូវពិនិត្យមើលឱ្យតែដឹងអ្នកណាមានធាតុសេរី និងខ្លាចសមរភូមិរាយការណ៍ឱ្យ គាត់ចាំគាត់អប់រំ ។ ក្រោយពីបងស៊ីមគាត់បានណែនាំមកខ្ញុំនិងមិត្តគុយ ទូច បានពិនិត្យ មើលដែរតែគ្មានឃើញអ្នកណាសេរីនិងខ្លាចសមរភូមិទេ ។

អង្គភាពរបស់ខ្ញុំនៅសំរាក់ជិតភ្នំនិងបានប្រហែល១ខែ នឹងត្រូវមកវៃនៅសមរភូមិទន្លេ បាសាក់ ពេលនេះបងស៊ីម មិត្តគុយ មិត្តទូចក៏មកជាមួយគ្នាទាំងអស់ដែរ ពេលនេះបងស៊ីម គាត់បានសួរខ្ញុំថា ម៉េចទៅខ្ញុំអាចទាក់ទងកម្លាំងបានទៀតទេ ខ្ញុំថាខ្ញុំពិនិត្យមើលដែរ តែអត់មានអ្នកសេរីទេ គាត់បានណែនាំបន្ថែមទៀតថាឱ្យខិតខំពិនិត្យបន្តទៀតទៅ ថ្ងៃមុខ ដើម្បីឱ្យបានកម្លាំងច្រើន ដូច្នេះជាបណ្ដើរៗយើងត្រូវធ្វើសកម្មភាពគេចមិន ទៅសមរភូមិ បំផុសកម្លាំងបដិវត្តឱ្យខ្លាចសមរភូមិ ។ល។

ពេលវៃនៅតាមផងទន្លេបាសាក់ បងស៊ីម មិត្តគុយ ទូច ខ្ញុំគេចមិនចូលសមរភូមិ ១ ផង ពេលមិត្តយើងចូលសំរុកពួកខ្ញុំទាំងអស់គ្នាពួនគេចមកដេកនៅខាងក្រោយ ។ ពេលរថក្រោះបុកខ្លាំងបងស៊ីមខ្ញុំ មិត្តគុយ ទូចបានបំផុសមិត្តយើងថារថក្រោះមកហើយប្រយ័ត្នរថក្រោះព័ទ្ធ ពេលនោះពួកខ្ញុំនាំរត់មុនគេមិត្តយើងក៏រត់ទាំងអស់គ្នា តែរត់បានបន្តិច ក៏គណៈវរៈសេនាធំបញ្ជាឱ្យទៅវិញ ហើយពួកខ្ញុំប៉ុន្មាននាក់នេះក៏រត់មកដល់ក្រោយ មកដេកនៅតាមខ្សែត្រៀមឈ្នាក់ការអត់ទៅវិញទេ ។

ក្រោយពីសភាពការផ្ទុះនៅភូមិភាគបូព៌ាហើយ អង្គភាពរបស់ខ្ញុំត្រូវឡើងទៅ វៃនៅភូមិភាគបូព៌ាទាំងអស់ ។ ពេលនេះមិត្តគុយនិងមិត្តទូចត្រូវអត់បានទៅភូមិភាគបូព៌ា

ទេ    គឺត្រឡប់ទៅភូមិភាគនិរតីវិញ    នៅតែខ្ញុំនិងបងស៊ីមជាប់គ្នាទៀត ។
ពេលទៅដល់ភ្លាមគឺចូលសមរភូមិស្រុកសំរោងភ្លាម  បានប្រហែល១ខែខ្ញុំក៏ត្រូវរបួសមកដេក
ពេទ្យ៦មករាភ្នំពេញអស់រយៈ១ខែកន្លះទើបចេញទៅកងវិញ ។

ពេលមកដល់អង្គភាពរបស់ខ្ញុំកងពិសេសត្រូវអង្គការបញ្ជូលទៅនៅកងពិសេសប្រចាំ
វរៈសេនាធំ៣២ កងពល៧០៣ ។ ខ្ញុំនៅក្នុងកងជាមួយបងស៊ីមដដែល ខ្ញុំមិនទាន់បានទៅស
មរភូមិទេព្រោះខ្ញុំនៅពីរបួសនៅសំរាក់កន្លែងសេដ្ឋកិច្ចខាងក្រោយ ។ កន្លះខែ-
ក្រោយមកខ្ញុំបានធ្វើការទាក់ទងជាមួយឈ្មោះ ម៉េង ម្នាក់ ពីដើមនៅកងពិសេសជាមួយគ្នា
កាលនៅតំបន់៣៥ បច្ចុប្បន្ននេះដកពីធំកងពិសេសជាយុទ្ធជននៅកងវរៈសេនាតូច២១វរៈ
សេនាធំ៣២ កងពល៧០៣ ។

ដំបូងខ្ញុំឃើញគាត់មិនដែលទៅសមរភូមិមុខនៅតែក្រោយជាមួយខ្ញុំ ខ្ញុំក៏ទៅសួរគាត់ថា -
ម៉េចហើយបានអត់ទៅមុខម៉េង ម៉េងប្រាប់ខ្ញុំថាមិនបានទេសមរភូមិនេះមីនច្រើនណាស់ ខ្ញុំ
ខ្លាចមីនណាស់មិនហ៊ានទៅសមរភូមិទេបានជាខ្ញុំគេចមកក្រោយវិញនេះ ។ ដើម្បីដេកលិន
ព្រោះនៅសមរភូមិមុខមិនដែលបានដេកទេ ពេលនេះខ្ញុំក៏ថាខ្ញុំក៏មិនហ៊ានទៅដែរទុក
ឱ្យគេវៃទៅ គេបានឯករាជ យើងក៏បានឯករាជដែរ ។
ដល់យប់ឡើងពេលដេកជាមួយគ្នា ខ្ញុំបានសួរទៅមិត្តម៉េងថា ចម្រៀងសង្គមចាស់ និងបដិវត្ត
ម៉េងឯងចាំខាងណាដាច់ ព្រោះខ្ញុំចម្រៀងបដិវត្តមិនចាំស្មោះស្តាប់បានតែបន្តិចៗភ្លេចអស់
បើពីចម្រៀងពីសង្គមចាស់ខ្ញុំនៅចាំខ្លះៗ មិត្តម៉េងថាគាត់ក៏អញ្ចឹងដែរចម្រៀងបដិវត្ត
ស្តាប់បានតែបន្តិចៗភ្លេចអស់ហើយ បើពីសង្គមនៅចាំខ្លះដែរ ព្រោះពីដើមសប្បាយណាស់
មានគេច្រៀងរាំវង់តគោកគដីទេ និយាយគ្នាហើយក៏នាំគ្នាច្រៀងចម្រៀងពីសង្គម
ចាស់ពីរបីបទម្នាក់ លួចតែបទរាំវង់សារាវ៉ាស ។

ដល់ថ្ងៃក្រោយមកទៀតខ្ញុំទៅពីកន្លែង សេដ្ឋកិច្ចទៅសំរាក់នៅកន្លែងកងសំរាក់
ខាងក្រោយខែ៦ក្រៀមមួយ ពេលនេះមានឈ្មោះបងអានកងហាររបស់ខ្ញុំ បច្ចុប្បន្នដក
ពីកងហាកងពិសេសទៅកាន់កងហាវរៈសេនាតូច២២ វរៈសេនាធំ៣២ កងពល៧០៣ ។

ពីដើមមកនៅកងតំបន់កំពតដែរ តែក្រោយមកលើពេកអង្គការដក ឱ្យទៅនៅសាធារណៈការតំបន់កំពតវិញ ទើបតែពេលទៀងមកភូមិ បូព៌ានេះបានអង្គការយកមកឱ្យនៅកងពិសេសវិញ ។

គាត់បានសួរមកខ្ញុំថា ទើបមកពីណា ខ្ញុំថា ទើបមកពីដកពេទ្យ គាត់បើទើបមកពីដក ពេទ្យក៏មិនដែលឃើញនៅឯណា ខ្ញុំថានៅសំរាកកន្លែងសេដ្ឋកិច្ចក្រោយ ខ្ញុំសួរគាត់ថាឯង ឯងមកយូរហើយ គាត់ថាទើបមកដែរ គាត់សួរខ្ញុំទៀតថា ម៉េចមកកន្លែងនេះស្រួលទេ ឯងមកកន្លែងនេះស្មុគស្មាញណាស់ហ្ន៎ នៅខាងមុខពិបាកស៊ីណាស់ បើមកនៅខាងក្រោយគ្រាន់ បានរកម្ហូបឯកជនស៊ីឆ្ងាញ់ស្រួលទេមិត្តខ្ញុំ ខ្ញុំថាស្រួលព្រោះនៅមុខស៊ីតែសាគោកគ្មានសម្លរ ដូចនៅក្រោយទេ ។ គាត់សួរទៀតថាមិត្តខ្ញុំឯងឃើញរបបឯកជន និងសមូហភាពខាង ណាស្រួលជាង "ខ្ញុំថារបបឯកជនស្រួលជាង" គាត់ថាមែនរបបឯកជនស្រួលជាងចង់ហូប អីបានតាមចិត្ត មិនដូចសមូហភាពទេ ចង់ធ្វើអីទាល់តែសមូហភាពកំណត់ទើបធ្វើបាន ព្រោះបក្ស កំណត់ទាំងអស់ ។

ក្រោយពីខ្ញុំភ្ជាប់បានមកក៏ខ្ញុំទៅរាយការណ៍ឱ្យបងស៊ុមថា ខ្ញុំភ្ជាប់បានពីរនាក់អាចឈ្លប ទាញឱ្យធ្វើសកម្មភាពជាមួយយើងបាន គឺ មានឈ្មោះ បងអាន មិត្តម៉េង ។ បងស៊ុមគាត់ណែនាំខ្ញុំថាមិនអីទេចាំគាត់ទៅអូសទាញ ខិតខំភ្ជាប់មើលអ្នកណាឱ្យបានថែមទៀត តែត្រូវលាក់ការណ៍កុំឱ្យបែកការ ដើម្បីយើងប្រមូលកម្លាំងយើងឱ្យបានច្រើន ធ្វើសកម្មភាពបន្ត ទៀត ។ ហើយសកម្មភាពក្នុងសមរភូមិគឺយើងត្រៀមធ្វើដែរ ។

ខ្ញុំរាយការណ៍ឱ្យបងស៊ុមដូចហើយបានប្រហែលកន្លះខែបងស៊ុមបានប្រាប់ខ្ញុំថាគាត់អប់រំ បងអាន មិត្តម៉េងបានហើយឱ្យខ្ញុំនេះធ្វើសកម្មភាពជាមួយគ្នាចុះ ហើយណែនាំឱ្យមិត្តម៉េង គេជួយពិនិត្យមើលអ្នកណាអាចអូសទាញបានឱ្យរាយការណ៍ដើម្បីប្រមូលកម្លាំងឱ្យបានច្រើន ។

ក្រោយពីបានដឹងគ្នាមកបងអាន មិត្តម៉េង ខ្ញុំបានធ្វើសកម្មភាពដើរលើនាំគ្នាដើរ ដឹកដំឡូងមកស្នាហូប តាមភូមិប្រជាជនដែលគាត់មិននៅដោយគ្នានក្រុមអ្នកទទួលខុសត្រូវ ជាបន្តបន្ទាប់ មានថ្ងៃមួយបងអាន បាននាំខ្ញុំនិងមិត្តម៉េងទៅដឹកដំឡូងមកស្នាហូបអត់ប្រាប់គេ

ហើយថ្ងៃនោះត្រូវថ្ងៃកងទៅប្រជុំកន្លែងវិរៈសេនាធំដើម្បីទទួលផែនការថ្មីនៅ៣០កញ្ញា ផងគេដើររកខ្ញុំទាំង៣នាក់អត់ឃើញ ក៏មិត្តយើងទៅចោលអស់ ដល់ខ្ញុំមកពីជីកដំឡូងវិញ ទើបមកតាមមិត្ត ហើយ នៅកន្លែងប្រជុំវិរៈសេនាធំឯណុះ ។

ពេលមកពីប្រជុំវិញបានដឹងគណៈវិរៈសេនាធំប្រកាសផែនការត្រូវទៅវ៉ៃសមរភូមិស្រុកលំនៅរាងនៅថ្ងៃ៣០កញ្ញា៧៨នេះ ក៏បងស៊ឹមបងអានគាត់បានណែនាំខ្ញុំនិងមិត្តម៉ឹង ថាមិត្តឯងចូលវ៉ៃនៅសមរភូមិនេះត្រូវធ្វើសកម្មភាពចលនាគេថាយួនក៏ធ្ងន់ហើយដកគុមក្រោយ វិញ ដើម្បីកុំឱ្យអង្គការយកជ័យជំនះបានក្នុងយប់ថ្ងៃ៣០នេះ និងឱ្យខូចខាតដល់កម្លាំងបដិវត្តផង ។

ដល់ថ្ងៃ៣០កញ្ញាបងស៊ឹមបងអានគាត់អត់ទៅទេថាឈឺ ខ្ញុំនិងមិត្តម៉ឹងត្រូវទៅនៅជាមួយមិត្តយើងអ្នកថ្មីពុមានភារៈកិច្ចវ៉ៃពីក្នុងមកក្រៅវិញ ពេលធ្វើដំណើរទៅខ្ញុំនិងម៉ឹងនៅជាប់ជាមួយគ្នា ទៅជិតដល់បន្ទាយយួននាក់ដើរមុខគេប្រាប់ថែជានមីនផ្ទុះវ៉ៃបកការនាំគ្នារត់មករក្រោយវិញប្រហែល២០០ម ទៀបខ្សែត្រៀម ពេលនោះខ្ញុំនិងមិត្តម៉ឹងក៏បានបំផុសចលនាតាមខ្សែត្រៀមថាដកពួនសឹងមកពីក្រោយហើយ " ការពិតអត់មានយួនទេ " ហើយអ្នកនៅតាមខ្សែត្រៀមក៏នាំគ្នារត់ទាំងអស់គ្នារហូតមកដល់ខ្សែត្រៀមខាងក្រោយ បានគណៈវិរៈសេនាធំសួររកអ្នកណាឱ្យរត់ ពេលនោះរកមុខមិនទាន់ឃើញទេ ។ ហើយគណៈវិរៈសេនាធំ ក៏ បញ្ជាឱ្យឡើងវ៉ៃសារទៀត ខ្ញុំនិងម៉ឹងឮដូច្នេះក៏គេចអត់ទៅទៀតទេលើកនេះ ។ ចំពោះបងអានពេលនេះក៏អង្គការឱ្យទៅស្មើដឹងវិញដែរ ។ ថ្ងៃ៣តុលា៧៨ ខ្ញុំត្រូវអង្គការចាប់តែម្តង ។

ធ្វើនៅថ្ងៃទី២២.១០.៧៨.

អ្នកសួរ

ប្រាក់.ខន

ហត្ថលេខាអ្នកសារភាព

ឡាយ.ទៀន=ទូចខុំ

## បញ្ជីឈ្មោះដែលមានពាក់ព័ន្ធ

## ក្នុងប្រវត្តិសកម្មភាពក្បត់ទូចខ្ញុំ

១- សាត អតីតៈក្ដាប់មិនបាន កាលណោះប្រធានក្រុមនៅកងវរៈសេនាតូច៦៥- របស់តំបន់កំពត នីរតី បច្ចុប្បន្ននេះមិនដឹងយ៉ាងណាទេ ។

២- ទូច អតីតៈក្ដាប់មិនបាន បច្ចុប្បន្នយុទ្ធជននៅកងវរៈសេនាតូច៦៥របស់ តំបន់កំពត ភូមិភាគនីរតី ។

៣- គុយ អតីតៈក្ដាប់មិនបាន បច្ចុប្បន្នមេពួកនៅកងវរៈសេនាតូច៦៥ របស់ តំបន់កំពត ភូមិភាគនីរតី ។

៤- បងចន អតីតៈក្ដាប់មិនបាន កាលណោះគណៈវរៈសេនាធំតំបន់៣៥ ឆ្នាំ៧០អង្គការ ដកឱ្យទៅក្ដាប់រោងចក្រជីនៅទូកមាស បច្ចុប្បន្នក្ដាប់មិនបាន ។

៥- ទេត អតីតៈ ក្ដាប់មិនបាន បច្ចុប្បន្នកងហា នៅវរៈសេនាតូច៦៥ របស់តំបន់កំពត ភូមិភាគនីរតី ។

៦- សឿន ពីដើមមកមិនដែលស្គាល់ទេ បច្ចុប្បន្នអនុក្រុមទី៣ កងហាទី២ កងធំ៣៤ វរៈសេនាតូច៦៥ របស់តំបន់កំពត ភូមិភាគនីរតី ។

៧- ស៊ុម អតីតៈទាហាននិរទ័ខនៅកំពត បច្ចុប្បន្នកងហានៅកងពិសេសប្រចាំ វរៈសេនាធំ៣២ កងពល៧០៣ ។

៨- ទ៊ៃដ អតីតៈមិនដឹង កាលណោះគណៈវរៈសេនាធំ៥២ របស់តំបន់កំពត បច្ចុប្បន្នក្ដាប់មិនបាន ។

៩- ម៉េង ពីដើមនៅកងពិសេសតំបន់កំពតដែរ បច្ចុប្បន្នយុទ្ធជនដកពីកងពិសេស ទៅនៅវរៈសេនាតូច២១ វរៈសេនាធំ៣២ កងពល៧០២ ។

១០- អាន កាលមុននៅកងតំបន់កំពតដែរ ហើយសេរីដកទៅនៅសាខាគណៈការ មួយរយៈ ទើបថ្មីៗនេះមកនៅកងពិសេសវរៈសេនាធំ៣២ បច្ចុប្បន្ន កងហានៅវរៈសេនាតូច២២ វរៈសេនាធំ៣២ កងពល៧០៣ ។

* * *